**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ០៤៨ សរាចក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ស្ថានភាពពលរដ្ឋភៀសសឹក ផលប៉ះពាល់លើតំបន់ស៊ីវិល
## គិតពីម៉ោង៦ព្រឹក ថ្ងៃទី១០ ដល់ម៉ោង៦ព្រឹក ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិជ្រាបថា ចាប់តាំងពីបទឈប់បាញ់រវាងកម្ពុជា និងថៃ ចូលជាធរមាន កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥មក ភាគីទាំងសងខាងពុំបានផ្ទុះអាវុធដាក់គ្នានោះឡើយ។ ក៏ប៉ុន្តែ កម្ពុជាបានតាមដាន និងកត់ត្រាទុកនូវសកម្មភាពមិនស្មោះត្រង់ជាបន្តបន្ទាប់របស់ភាគីថៃ។ **ក្រសួងមហាផ្ទៃ** បានកំពុងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ខិតខំដោះស្រាយកិច្ចការអាទិភាពដើម្បីជួយដល់ប្រជាពលរដ្ឋ ព្រមទាំងស្តារឡើងវិញរាល់ការខូចខាត លើតំបន់ស៊ីវិល។ **ក្រសួងមហាផ្ទៃ** សូមផ្តល់ជូនបច្ចុប្បន្នភាពនៃសភាពការណ៍ជារួម គិតពីម៉ោង៦ព្រឹក ថ្ងៃទី១០ ដល់ម៉ោង៦ព្រឹក ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦ ដូចខាងក្រោម៖

**១-ស្ថានភាពពលរដ្ឋភៀសសឹក៖** មានពលរដ្ឋភៀសសឹក១.២៤០នាក់បន្ថែមទៀត បានបន្តវិលត្រឡប់ទៅលំនៅឋានវិញ។ ដូច្នេះ ក្នុងចំណោមពលរដ្ឋភៀសសឹកសរុបជាង៦សែន៤ម៉ឺននាក់ មានជាង៥សែន៦ម៉ឺននាក់ ឬជាង៨៧% បានវិលត្រឡប់ទៅលំនៅឋានវិញ។ នៅមានពលរដ្ឋចំនួន៨២.៣០៦នាក់ទៀត (ស្ត្រី៤៣.២៨៣នាក់ និងកុមារ២៧.៦៦៧នាក់) ពុំទាន់អាចវិលទៅលំនៅឋានវិញ។

**២-ការបន្តបិទផ្អាកសេវាសាធារណៈជាមូលដ្ឋាន៖ ខេត្តឧត្តរមានជ័យ** មានសាលារៀន១៤ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព៧ បន្តបិទផ្អាក។ **ខេត្តបន្ទាយមានជ័យ** មានសាលារៀន៥ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១ បន្តបិទផ្អាក។ **ខេត្តព្រះវិហារ** មានសាលារៀន២៩ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ នៅបន្តបិទផ្អាក។

**៣-ការខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖** គិតចាប់ពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥មក ការខូចខាតទ្រព្យសម្បត្តិសាធារណៈ និងឯកជន ពុំទាន់មានរបាយការណ៍ថ្មីបន្ថែមលើករណីដែលក្រសួងបានកត់ត្រាទុកនៅឡើយទេ។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** គាំទ្រពេញទំហឹងលើការតវ៉ាដាច់អហង្ការរបស់រាជរដ្ឋាភិបាលចំពោះយោធាថៃ ដែលបានធ្វើសកម្មភាពជាបន្តបន្ទាប់ ផ្ទុយពីខ្លឹមសារនៃសេចក្តីប្រកាសរួម កិច្ចប្រជុំពិសេសលើកទី៣នៃគណៈកម្មាធិការព្រំដែនទូទៅ(GBC) ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ **ក្រសួង** ក៏សូមគោរពស្ញប់ស្ញែងដ៏ខ្ពង់ខ្ពស់ចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃកម្ពុជា ដែលបានសង្កត់ធ្ងន់យ៉ាងម៉ឺងម៉ាត់ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦ថា **ព្រំដែនកម្ពុជា-ថៃ គឺជាព្រំដែនអន្តរជាតិរវាងរដ្ឋ និងរដ្ឋ និងដែលរាជរដ្ឋាភិបាលប្តេជ្ញាការពារអធិបតេយ្យ បូរណភាពទឹកដី និងប្រជាជន ទាំងបច្ចុប្បន្ន និងអនាគត ដោយផ្អែកលើច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងដែលមានស្រាប់របស់ភាគីទាំងពីរ ដោយមិនទទួលស្គាល់ដាច់ខាត ការកាន់កាប់ទឹកដីគ្រប់រូបភាពតាមរយៈការប្រើកម្លាំងខុសច្បាប់។**

ក្នុងន័យនេះ **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមអំពាវនាវមិត្តអាស៊ាន មិត្តបរទេស និងអង្គការសហប្រជាជាតិ បន្តចូលរួមគាំទ្រការដោះស្រាយជម្លោះព្រំដែនកម្ពុជា-ថៃ តាមគោលការណ៍សន្តិវិធី ស្របតាមច្បាប់អន្តរជាតិ ដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាពសម្រាប់ប្រជាជនទាំងសងខាង ក្នុងតំបន់ និងសកលលោក។ យើងក៏សូមអំពាវនាវជនរួមជាតិរួបរួមគាំទ្រ និងជឿជាក់លើការដឹកនាំរបស់ **សម្តេចមហាបវរធិបតី** ដើម្បីដោះស្រាយបញ្ហាព្រំដែនតាមគោលការណ៍សន្តិវិធី ច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងជាធរមាន និងសូមក្តោបស្មារតីរួមមួយថា **ជម្លោះទឹកដីនេះពិតជាបង្កការឈឺចាប់ ប៉ុន្តែយើងមិនត្រូវដួលដោយសារការឈឺចាប់នេះជាដាច់ខាត ផ្ទុយទៅវិញគឺត្រូវប្រែក្លាយការឈឺចាប់នេះឱ្យទៅជាភាពរឹងមាំនៃជាតិ និងប្រជាជនយើង។**

ថ្ងៃពុធ ៩រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦